**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

*ថ្ងៃ ចន្ទ ១២ កើត ខែ បឋមាសាឍ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស ២៥៦៥*

*រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០២១*

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពីជំនួបពិភាក្សាការងាររវាងឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយលោកជំទាវ EVA Nguyen Binh ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋបារាំង ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា

នៅរសៀលថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០២១, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទទួលជួបលោកជំទាវ EVA Nguyen Binh ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋបារាំង ដើម្បីសម្តែងការគួរសម និងជម្រាបលា ក្នុងឱកាសដែល លោកជំទាវនឹងបញ្ចប់អាណត្តិបេសកកម្មការទូតនៅកម្ពុជា នៅថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០២១ ខាងមុខនេះ តាមប្រព័ន្ធ Video Conference ។

ក្នុងឱកាសនេះ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោកជំទាវ EVA Nguyen Binh ដែលបានបំពេញបេសកកម្មការទូតនៅកម្ពុជា ក្នុងរយៈពេល ០៤ឆ្នាំ (ឆ្នាំ២០១៧-ឆ្នាំ២០២១) ហើយបានកសាងស្នាដៃ និងសមិទ្ធផលជាច្រើន ក្នុងការរួមចំណែកដល់សកម្មភាពអភិវឌ្ឍន៍ដល់សេដ្ឋកិច្ច-សង្គមកម្ពុជា ស្ទើរគ្រប់វិស័យ ជាពិសេស វិស័យសុខាភិបាល ទឹកស្អាត អគ្គិសនី កសិកម្ម និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏ដូចជាសម្រេចបាននូវគម្រោងវិនិយោគសាធារណៈជាច្រើន ផ្សេងទៀត ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ក៏បានលើកឡើងថា សាធារណរដ្ឋបារាំង មិនត្រឹមជាប្រទេស ដែលបានចូលរួមក្នុងសកម្មភាពនាំសុខសន្តិភាពដល់ប្រទេសកម្ពុជាប៉ុណ្ណោះទេ តែក៏ជាមិត្តដ៏ប្រពៃ ដែលតែងតែជួយគាំទ្រទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ដល់ការអភិវឌ្ឍកម្ពុជា ។ ជាក់ស្តែង, តាមរយៈកិច្ចប្រជុំពិគ្រោះយោបល់កន្លងទៅដែលដឹកនាំដោយលោកជំទាវ, រដ្ឋាភិបាលបារាំង តាមរយៈ AFD បានសន្យាថា នឹងបង្កើនទំហំឥណទានសម្បទាន ក្នុងចន្លោះពី ១០០-១២០ លានអឺរ៉ូ ក្នុងមួយឆ្នាំ និងថែមទាំងជួយគៀរគហិរញ្ញប្បទានឥតសំណងពីសហគមអឺរ៉ុប និងពីប្រភពផ្សេងទៀតផងដែរ សម្រាប់រួមចំណែកក្នុងការអភិវឌ្ឍន៍ និងស្តារសេដ្ឋកិច្ចកម្ពុជាបន្ទាប់ពីវិបត្តិកូវីដ-១៩ តាមគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់កម្ពុជា ។

**លោកជំទាវឯកអគ្គរដ្ឋទូត** នៃសាធារណៈរដ្ឋបារាំងបានលើកឡើងថា ជាការពិតកម្ពុជា និង បារាំង មានទំនាក់ទំនងយូរអង្វែងមកហើយ ពិសេស កិច្ចសហការប្រតិបត្តិការអភិវឌ្ឍន៍ជាមួយ AFD ។ កិច្ចសហប្រតិបត្តិការនេះ គឺបានចូលរួមចំណែកដ៏សំខាន់ក្នុងការធ្វើប្រតិបត្តិការអភិវឌ្ឍន៍របស់ ប្រធានាធិបតីបារាំង Emmanuel Macron ដែលបានប្តេជ្ញាសម្រេចគោលដៅ ក្នុងការបង្កើនហិរញ្ញប្បទានសហប្រតិបត្តិការ ODA ឲ្យបាន ០,៥៥% នៃផសស នៅឆ្នាំ ២០២២ ដើម្បីចូលរួម អភិវឌ្ឍន៍ ឿនសេដ្ឋកិច្ចរបស់ប្រទេសកំពុងអភិវឌ្ឍន៍ ពិសេសកម្ពុជា ដោយផ្តោតជាសំខាន់ទៅលើការបម្រែបម្រួលអាកាសធាតុ ស្របតាមខ្លឹមសារនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស ឆ្នាំ២០១៥ ។ **លោកជំទាវ** ក៏ បានវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់ **សម្តេច តេជោនាយករដ្ឋមន្ត្រី** ដែលសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ និងប្រកប ដោយចីរភាពក្នុងរយៈ ពេលជាងពីរទសវត្សរ៍កន្លងមកនេះ ។ ជាមួយគ្នានេះ, លោកជំទាវក៏សម្តែងនូវមោទនភាពដែលរាជរដ្ឋាភិបាលកម្ពុជា បង្កបរិយាកាសវិនិយោគឯកជនដ៏ល្អប្រសើរ និងលើកទឹកចិត្តវិនិយោគិនបរទេស ពិសេស មកពីប្រទេសបារាំងឱ្យមកស្វែងយល់ផ្ទាល់ និងបណ្តាក់ទុនវិនិយោគនៅកម្ពុជា ។

**លោកជំទាវ** ក៏បានសម្តែងនូវការគាំទ្រយ៉ាងពេញទំហឹង ចំពោះចំណាត់ការ និងវិធានការ នានា ដែលរាជរដ្ឋាភិបាលបាននិងកំពុងដាក់ចេញ ក្នុងការប្រយុទ្ធទៅនឹងការរាលដាលនៃជម្ងឺកូវីដ-១៩ ។ ការដាក់ចេញនូវគោលការណ៍ ៣ កុំ ៣ ការពារ, វិធានការបិទខ្ទប់ដោយគ្មានការបិទ ប្រទេស ទាំងមូល និងការជំរុញយ៉ាងសកម្មក្នុងការចាក់វ៉ាក់សាំងប្រឆាំងជំងឺកូវីដ-១៩ ជាដើម ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ក៏បានជម្រាបជូនលោកជំទាវឯកអគ្គរដ្ឋទូត ថា កម្ពុជាបានដាក់ចេញនូវ **"ផែនការយុទ្ធសាស្ត្រយុទ្ធនាការជាតិ ចាក់វ៉ាក់សាំងបង្ការជំងឺ កូវីដ-១៩"** សំដៅបង្កើតឱ្យបាននូវភាពស៊ាំសង្គម-សេដ្ឋកិច្ចនៅកម្ពុជា ក្នុងឆ្នាំ ២០២១ ។ ពោលគឺការចាក់វ៉ាក់សាំង បង្ការជំងឺកូវីដ-១៩ ដល់ប្រជាជនចាប់ពីអាយុ ១៨ ឆ្នាំឡើងទៅឱ្យបានគ្រប់ៗគ្នានៅទូទាំងប្រទេស ។ ជាមួយគ្នានេះ, ដើម្បីឆ្លើយតបទៅនឹងបរិការណ៍បច្ចុប្បន្ន, ក្នុងខណៈបន្តប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩, កម្ពុជា បានដាក់ឱ្យអនុវត្តនូវវិធានការអន្តរាគមន៍ជាច្រើន រួមជាមួយនឹងការគិតគូរជាយុទ្ធសាស្ត្រ បន្តអនុវត្តនូវគោលនយោបាយហិរញ្ញវត្ថុសាធារណៈ គោលនយោបាយរូបិយវត្ថុ និងវិធានការកែ ទម្រង់រចនាសម្ព័ន្ធ សំដៅរក្សាលំនឹងសេដ្ឋកិច្ច និងសង្គម ក៏ដូចជា ជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ បន្ទាប់ពីជំងឺកូវីដ-១៩ តាមរយៈ បន្តបង្កើនភាពប្រកួតប្រជែង, បន្តជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ច និង បន្តជំរុញការកែទម្រង់រចនាសម្ព័ន្ធ ។ រាជរដ្ឋាភិបាលកម្ពុជា បានផ្តល់អាទិភាពខ្ពស់ចំពោះផែនការយុទ្ធ សាស្ត្រនៃការស្តារសង្គម-សេដ្ឋកិច្ចឡើងវិញ តាមរយៈអភិក្រមចំនួនបីគឺ÷ ការស្តារឡើងវិញ, ការកែ ទម្រង់ និងការកសាងភាពធន់ ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ក៏បានសម្តែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោកជំទាវអគ្គរដ្ឋទូត រដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង និងប្រជាជនបារាំង ដែលបាននិងបន្តគាំទ្រ ទាំងជំនាញបច្ចេកទេស និងទាំងហិរញ្ញវត្ថុ រួមចំណែកដល់ការអភិវឌ្ឍន៍ប្រទេសកម្ពុជា និងជូនពរលោកជំទាវ ឱ្យបានទទួលជោគជ័យថ្មីៗជាបន្តបន្ទាប់ទៀត នៅក្នុងភារកិច្ចដ៏ឧត្តុងឧត្តមរបស់លោកជំទាវ ។